# អត្ថបទអំពី៖ ពិធីបុណ្យសែនព្រះខែ

ជារៀងរាល់ឆ្នាំយើងតែងតែឃើញប្រជាជនចិន, ប្រជាជនខ្មែរជាប់សែស្រឡាយចិន និងបណ្ដាប្រជាជនក្នុងប៉ែកអាស៊ីជាច្រើនប្រទេស ធ្វើការប្រារព្ធពិធីបុណ្យសែនព្រះខែ ដែលស្ថិតនៅកណ្ដាលរដូវស្លឹកឈើជ្រុះ ពិធីនេះដែរគេច្រើនប្រារព្ធឡើងនៅថ្ងៃទី ១៥ ក្នុងខែទី៨របស់ចិន ហើយត្រូវនឹងខែ កញ្ញា ឬតុលានៃប្រតិទិនសុរិយគតិរបស់ខែ។






**ពិធីបុណ្យសែនព្រះខែ**

## ១.ប្រវត្តិនៃពិធីសែនព្រះខែ

តាមឯកសារទំនៀមទម្លាប់ប្រពៃណីចិន បុណ្យសែនព្រះខែកើតឡើងតាំងពីសម័យរជ្ជកាល ជូ ឆ្នាំ ១០៤០-២៥៦ មុនគ្រិស្តសករាជមកម្ល៉េះ តែគេឃើញកាលនោះមានប្រារព្ធធ្វើតែក្នុងក្រុមគ្រួសាររាជវង្សប៉ុណ្ណោះ។ ក្រោយមករជ្ជកាល សួយ ឆ្នាំ៥៨១-៦១៨ និងសម័យរជ្ជកាល ថាង ឆ្នាំ៦១៨-៩០៧ នៃគ្រិស្តសករាជ ជនជាតិចិនគ្រប់ស្រទាប់វណ្ណៈបានប្រារព្ធធ្វើយ៉ាងទៀងទាត់ទៀតផង។ រហូតដល់សម័យរជ្ជកាល សុង ឆ្នាំ៩៦០-១១២៧ បុណ្យសែនព្រះខែនេះ ជនជាតិចិនប្រារព្ធធ្វើជាសកលនៅគ្រប់ទិសទីរហូតមកទល់នឹងបច្ចុប្បន្ននេះ។[1]

ចំពោះពិធីបុណ្យនេះក៏មានរឿងព្រេងដំណាលថា ក្នុងអតីតកាលបុរាណរបស់ចិន មានវីរបុរសម្នាក់ល្បីឈ្មោះមួយរូបឈ្មោះ **ហូខ យី** ដែលមានស្នាដៃល្អបំផុតក្នុងការបាញ់ធ្នូ ហើយលោក **ហូខ យី** ក៏មានប្រពន្ធដែលមានសម្រស់ដ៏



ការបែកគ្នារវាងអ្នកទាំងពីរ



**ហូខយី** ធ្វើការបាញ់ទម្លាក់ព្រះអាទិត្យ

[1] សៀវភៅជនជាតិចិនភាគតិចនៅកម្ពុជា ( accessed September 19, 2021 at 9:30 am )

ស្រស់ស្អាតមួយរូបឈ្មោះថា **ឆាងអឺ**។ កាលសម័យនោះ កើតមានព្រះអាទិត្យ ចំនួន ១០ នៅលើមេឃ បណ្តាលឱ្យមនុស្ស សត្វ និង រុក្ខជាតិ ជួបនៅគ្រោះមហន្តរាយ។



**ហូងយី និង ឆាងអឺ ជាភរិយា**

ដោយពេលនោះដែរ **ហូងយី** បានធ្វើការបាញ់ប្រហារព្រះអាទិត្យ ចំនួន ៩ ឱ្យនៅសល់តែមួយគត់ ដើម្បីផ្តល់នូវពន្លឺដល់ប្រជានុរាស្ត្រ។ ពេលនោះដែល **ហូងយី** បានក្លាយទៅជាវីរបុរសរបស់ប្រជាជនចិន។ ស្តេចមានការកោតសរសើរដល់ **ហូងយី** ជាខ្លាំង និងបានផ្តល់នូវថ្នាំអមតៈ ដែលអាចឱ្យគាត់ហោះហើរទៅលើមេឃបាន។ ប៉ុន្តែអ្វីដែលជាបញ្ហា គឺទឹកថ្នាំនោះមានតែមួយដបហើយសម្រាប់តែមនុស្សម្នាក់គត់។ **ហូងយី** មិនចង់ចាកចេញពីប្រពន្ធរបស់គាត់ឡើយ គាត់ក៏បានឱ្យ **ឆាងអឺ** រក្សាទឹកថ្នាំនេះទុក។ ប៉ុន្តែ **ម៉េងម៉េង** ដែលជាសិស្សម្នាក់ក្នុងចំណោមសិស្សរបស់គាត់បានដឹងការសម្ងាត់នេះ។ នៅថ្ងៃទី១៥ ខែសីហា នៅក្នុងប្រតិទិន នៅពេលដែល **ហូងយី** បានទៅបរបាញ់សត្វ **ម៉េងម៉េង** បានចូលទៅក្នុងផ្ទះរបស់ **ហូងយី** និង បង្ខំឱ្យ **ឆាងអឺ** ប្រគល់ថ្នាំអមតៈនោះមកឱ្យគេ។ **ឆាងអឺ** មិនយល់ព្រម ហើយនាងបានផឹកទឹកថ្នាំនោះចូលទៅក្នុងពោះ រួចក៏ហោះទៅលើមេឃបាត់ទៅ។ នាងស្រឡាញ់ស្វាមីជាខ្លាំងណាស់ ហើយសង្ឃឹមថានឹងរស់នៅក្បែរគ្នាជារៀងរហូត ទើបនាងជ្រើសរើសព្រះចន្ទសម្រាប់ធ្វើជាលំនៅឋាន។ នៅពេលដែល **ហូងយី** ត្រឡប់មកវិញ គាត់បានដឹងពីអ្វី ដែលបានកើតឡើង គាត់មានអារម្មណ៍សោកស្តាយជាខ្លាំង។ ដើម្បីជាការរំលឹកដល់ភរិយា គាត់បាននាំយកផ្លែឈើ និងនំ ដែល **ឆាងអឺ** ចូលចិត្តទៅ ឧទ្ទិសដល់នាង ដែលរស់នៅក្នុងឋានព្រះចន្ទ មនុស្សដែលបានដឹងអំពីសកម្មភាពទាំងអស់នេះ ក៏ចាប់ផ្តើមចូលរួមនៅក្នុងការបូជាសែនរបស់ទាំងនេះ ជាមួយ **ហូងយី**។ ចាប់តាំងពីពេលនោះមក ទម្លាប់នៃការបូជាដល់ព្រះចន្ទ ក៏ត្រូវបានរីករាលដាលពាសពេញប្រទេសតាំងពីពេលនោះមក។ មនុស្សបានថ្វាយបូជាដល់ **ឆាងអឺ** ដើម្បីរំលឹកដល់នាង ដែលមានភក្តីភាពចំពោះស្វាមី និងរស់នៅក្នុងព្រះចន្ទតែម្នាក់ឯង ហើយក៏បួងសួងសុំសេចក្តីសុខ និងសំណាងល្អ ដល់អ្នកជំនាន់ក្រោយផងដែរ។[2]

## ២. អត្ថន័យ និង របៀបសែនព្រះខែ

បុណ្យសែនព្រះខែ ជាពិធីបុណ្យសំខាន់មួយ ក្នុងប្រតិទិនរបស់ចិន។ តាមប្រពៃណីគឺ ញាតិមិត្ត និង មិត្តភ័ក្តិ មកជួបជុំគ្នានៅថ្ងៃនេះ ដើម្បីមើលព្រះខែពេញបូណ៌មី និង ញ៉ាំនំលោកខែជុំគ្នា។ ក្នុងពិធីបុណ្យនេះ ក៏មានគ្រឿងរណ្តាប់ដូចជា៖

---

[2] ប្រវត្តិនៃពីធីបុណ្យ «សែននំព្រះខែ»
https://www.kampucheathmey.com/belief/685/ ( accessed September 19, 2021 at 10:30 am )

- ការកាន់គោម ដុតគោម និង បង្ហោះគោម
- អុជធូប និងសែននំ ជាច្រើនប្រភេទ ដើម្បីជាការគោរពដល់ទេពធីតា ឆាងអឺ
- រាំរបាំភ្លើងតោនាគជាដើម[3]

ខណៈឯ ក្នុងអំឡុងពេលបុណ្យសែននំព្រះខែនេះ អ្វីដែលប្រជាជនចិន ប្រជាជនខ្មែរជាប់សែស្រឡាយចិន និង ប្រទេសផ្សេងៗទៀត តែងតែនិយមធ្វើក្នុងពេលបុណ្យប្រពៃណីដ៏ធំមួយនេះ ដើម្បីទទួលបានពរជ័យ និង ហុងស៊ុយ ពេញមួយជីវិតពួកគេ និងនាំមកនូវប្រយោជន៍ដូចតទៅះ

**១. ទទួលទានអាហារពេលល្ងាចជាមួយគ្រួសារ**

ដោយសារពិធីបុណ្យនេះចាប់ផ្ដើម នៅពាក់កណ្ដាល រដូវស្លឹកឈើជ្រុះ ដែលតំណាលពីការជួបជុំក្រុមគ្រួសារ និងទទួលទានអាហារពេលល្ងាចជាមួយគ្នានៅវេលាយប់។ មនុស្សដែលមិនមានពេលនៅជាមួយឪពុកម្ដាយ ពួកគេនឹងព្យាយាមវិលត្រឡប់ទៅផ្ទះយ៉ាងហោចណាស់បានទទួលទានអាហារពេលល្ងាចរួមគ្នា។

**២. ទទួលទាននំសែនព្រះខែជុំគ្នា**

នំសែនព្រះខែ គឺជានំប្រពៃណីចិន ដែលបានធ្វើចេញពីម្សៅស្រូវសាលី ស្ករ និង ម្សៅគ្រាប់ឈូក សណ្ដែកក្រហម.......។ នំនេះជានិមិត្តរូបនៃការជួបជុំគ្រួសារ នឹងត្រូវបានកាត់ជាចំណែកស្មើៗគ្នា តម្រូវតាមចំនួនមនុស្សនៅក្នុងគ្រួសារ។ នៅលើនំសែនព្រះខែ មានបោះជាតួអក្សរចិនដែលមានន័យថា "ភាពយូរអង្វែង" និង "ភាពសុខដុមរមនា" ការតុបតែងបន្ថែមទៀតដូចជា រូបព្រះចន្ទ រូបទេពធីតា **ឆាងអឺ** និង រូបទន្សាយ (ទន្សាយក៏តំណាងឱ្យព្រះចន្ទដែរ)។

**៣. ផ្ដល់តម្លៃដល់ព្រះចន្ទ ដែលជានិមិត្តរូបនៃការជួបជុំគ្រួសារ**

តាមជំនឿចិន ព្រះចន្ទ គឺជានិមិត្តរូបសម្រាប់ការជួបជុំគ្រួសារ។ អ្នកនិពន្ធកំណាព្យបុរាណល្បីៗ ជាច្រើនបានសរសេរកំណាព្យអំពីព្រះចន្ទ និងបង្ហាញពីភាពកក់ក្ដៅរបស់ពួកគេ។ នៅពេលមនុស្សក្រឡេកមើលទៅព្រះចន្ទ ក៏អាចជួយរំលឹកពួកគេពីគ្រួសារ និងស្រុកកំណើតបានដែរ។

**៤. ថ្វាយបង្គំ ព្រះចន្ទ តាមប្រពៃណី**

បន្ទាប់ពីអាហារពេលល្ងាចរួចរាល់ គ្រួសារទាំងអស់ នឹងដាក់តុនៅខាងក្រៅទ្វារមុខផ្ទះ ឬនៅទីធ្លាទូលាយណាមួយ។ បន្ទាប់មកពួកគេដាក់នំសែនលោកខែ ផ្លែឈើ ធូប និង គោមនៅលើតុដោយបែរមុខទៅរកព្រះចន្ទ។ ផ្លែឈើសម្រាប់គោរពបូជាព្រះចន្ទរួមមាន ផ្លែឪឡឹក ក្រូចថ្លុង ផ្លែទទឹម ផ្លែទន្លាប់ ទំពាំងបាយជូរ ឬ ផ្លែឈើតាមរដូវផ្សេងទៀត។

**៥. ធ្វើអំពូលគោមពណ៌ប្លែកៗបំភ្លឺ**

[3] សែននំលោកខែ https://www.qoobuzzkh.com/topic/351 (accessed September 19, 2021 at 02:30 pm)

ចង្កៀងគោមមានរាងខុសៗគ្នាហើយក៏អាចស្រដៀង នឹងសត្វ រុក្ខជាតិ ឬ ផ្កាដែលត្រូវបានគេព្យួរនៅលើដើមឈើមុខផ្ទះ ឬ បណ្តែតទៅលើទន្លេជាដើម។ ជនជាតិចិនតែងតែទម្លាប់ធ្វើចង្កៀងគោមប្លែកៗ ដើម្បីទុកបំភ្លឺដល់ព្រះចន្ទជានិច្ច។

**៦. ផ្តល់អំណោយដល់មិត្តភ័ក្តិ សាច់ញាតិ និង បុគ្គលិក**

ក្នុងអំឡុងពេលនៃពិធីបុណ្យនេះកូនខ្មែរកាត់ចិនមួយចំនួន នឹងចំណាយពេលទៅលេងមិត្តភ័ក្តិ ឬសាច់ញាតិ ដោយយកអំណោយទៅជាមួយ។ ជាធម្មតាពួកគេចាកចេញមុនពេលអាហារពេលល្ងាច ហើយនេះគឺជាពេលវេលាដ៏ល្អដើម្បីជិតស្និទ្ធជាមួយមិត្តភ័ក្តិ និង សាច់ញាតិ។ ក្រុមហ៊ុន ក៏ចូលចិត្តផ្តល់អំណោយដល់បុគ្គលិកគ្រប់រូបផងដែរ។ អំណោយដែលពេញនិយមទូទៅគឺនំសែនព្រះខែ និង ផ្លែឈើ។

**៧. ទូរស័ព្ទ ឬ ផ្ញើសារអបអរសាទរដល់អ្នកដែលនៅឆ្ងាយ**

រឿងមួយទៀតដែលខ្មែរសែស្រឡាយចិននិយមធ្វើគឺទូរស័ព្ទទៅសួរសុខទុក្ខឬក៏ផ្ញើសារអបអរសារដល់មិត្តភ័ក្តិសាច់ញាតិ ឬ មនុស្សដែលនៅឆ្ងាយ។[4]



នំសែនព្រះ និង ការទទួលទាន់អាហារពេល

## ៣. សន្និដ្ឋាន

ចំពោះការប្រារព្ធពិធីបុណ្យសែនព្រះខែរបស់ប្រជាជនចិន ប្រជាជនខ្មែរជាប់សែស្រឡាយចិន និងប្រជាជនក្នុងប្រទេសអាស៊ី នេះក៏មានការប្រារព្ធធ្វើឡើងដូចគ្នា និង ខុសគ្នាបន្តិចបន្តួចទៅតាមប្រទេសនៅក្នុងប្រទេសអាស៊ីមានដូចជា ជប៉ុន, កូរ៉េខាងជើង, សិង្ហបុរី, ម៉ាឡេស៊ី, វៀតណាម និង ហ្វីលីពីនជាដើម.. ដែលតែងប្រារព្ធពិធីនេះនៅពេលកណ្តាលរដូវកាលស្លឹកឈើជ្រុះ ចន្លោះពេលខែកញ្ញា និង តុលា ជាឱកាសល្អក្នុងការជួបជុំគ្រួសារ ញាតិមិត្ត បងប្អូន ជិតឆ្ងាយ ដើម្បីធ្វើការអបអរពិធីសែនព្រះខែ ដោយមានការបរិភោគអាហារពេលល្ងាច បង្កើននូវភាពកក់ក្តៅក្នុងគ្រួសារ ធ្វើការបូជាសុំក្តីសុខពីទេពធីតា **ឆាងអឺ** និងការទទួលទាននំ សែនព្រះខែ ជុំគ្នា គយគន់ព្រះចន្ទពេញបូណ៌មី នាថ្ងៃពិធីបុណ្យ។ ចំពោះការប្រារព្ធពិធីបុណ្យនេះ ក្នុងប្រទេសចិនក៏ទទួលបានកើនចំណូលសេដ្ឋកិច្ចប្រមាណ ៧.៩% ពីការប្រារព្ធពិធីសែននំ

---

[4] ជំនឿនិងប្រពៃណីសែស្រឡាយរបស់ចិនអាក់ខានមិនបាន ក្នុងពិធីសែននំព្រះខែ
https://tnb-news.com/detail/242335.html ( accessed September 20, 2021 at 09:30 am )

លោកខែនេះ ស្មើនឹងទឹកប្រាក់ចំនួន(២.៧៧ ប៊ីលានដុល្លារ) ចំណែកឯការធ្វើដំណើរកម្សាន្តរបស់ប្រជាជនចិនក្នុងឱកាសឈប់សម្រាក់ពិធីបុណ្យសែនព្រះខែបានប្រមាណ ៧.៨% និង ចំណូលក្នុងវិស័យទេសចរណ៍ក្នុងស្រុកកើនឡើង ៨.៧% ស្មើនឹងទឹកប្រាក់ចំនួន( ៦.៧៣ ប៊ីលានដុល្លា) ទិន្នន័យគិតត្រឹមឆ្នាំ២០១៩។[5] ពិធីបុណ្យសែនព្រះខែនេះជាពិធីបុណ្យ ដែលមានការជួបជុំយ៉ាងសប្បាយរីករាយក្នុងក្រុមគ្រួសារ បង្កើនភាពកក់ក្ដៅ និង ចំណងមិត្តភាព។



ពិធីបុណ្យសែនព្រះខែ និង ការរំលឹកទេពធីតាឆាងអ៊ី

[5] China Economic Update Report – Asia Perspective https://asiaperspective.net/ap20/wp-content/uploads/2020/01/china-economic-update-2019Q3.pdf?x73343 ( accessed September 20, 2021 at 11:30 am )